# សេចក្តីថ្លែងការណ៍

## ភាពចាំបាច់នៃការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឱ្យបានពេញលេញ

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

**អបអរសាទរខួបទី ៣០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (២៣ តុលា ១៩៩១ - ២០២១)!**

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសគឺជាទិវាជាតិ ដ៏សំខាន់មួយដែលមានន័យជាប្រវត្តិសាស្រ្ត សម្រាប់ប្រជាជាតិខ្មែរទាំងមូល ។ ២៣ តុលា គឺជាទិវាដែលខ្មែរគ្រប់និន្នាការ ឬបក្សនយោបាយ និង ហត្ថលេខីទាំង ១៨ ប្រទេសផ្សេងទៀតបានស្រុះស្រួលមូលមតិគ្នាបញ្ចប់នូវសង្គ្រាម (មហាសោកនាដកម្ម រាប់ទសវត្សរ៍និងការឈ្លានពានរបស់បរទេសមកលើកម្ពុជាដែលបានបង្កឱ្យពលរដ្ឋខ្មែររងទុក្ខវេទនា និរាស ព្រាត់ប្រាស់និងបាត់បង់ជីវិតរាប់លាននាក់), ធានាអធិបតេយ្យភាព បូរណភាពទឹកដី ឯករាជ្យភាពនិង អព្យាក្រឹតភាពរបស់កម្ពុជា, និងរួមគ្នាកសាងកម្ពុជាឡើងវិញឱ្យក្លាយទៅជា "កោះសន្តិភាព" ដោយឈរលើ ស្មារតីសន្តិភាពនិងអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្សដោយធានាបាននូវការគោរពសិទ្ធិ, សេរីភាពនិងនីតិរដ្ឋ ដើម្បីបង្ការកុំឱ្យប្រវត្តិសាស្រ្តអតីតកាលដ៏ជូរចត់វិលត្រឡប់មកវិញបាន។

ទម្រាំមានថ្ងៃនេះ មនុស្សរាប់លាននាក់បានបូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុសន្តិភាព និងកម្ពុជា តាមរយៈកិច្ចព្រមព្រៀងនេះ។ យើងស្រមៃមើលថា៖ ប្រសិនជាគ្មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសទេ តើសោកនាដកម្មជាច្រើនដែលមិនអាចពិពណ៌នាបានទាំងនោះត្រូវបានបញ្ឈប់ឬទេ? ហើយ តើការឈឺចាប់និងមហន្តរាយអ្វីខ្លះទៀតដែលនឹងបន្តកើតមានទៀត?

ដោយមើលឃើញពីគុណតម្លៃជាសារវន្តនៃស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុង ប៉ារីស ២៣ តុលា ១៩៩១, យើងខ្ញុំជាអង្គការ សមាគម សហជីព សហគមន៍ និងប្រជាពលរដ្ឋខ្មែរ សូមស្នើដោយទទូច ដល់រដ្ឋាភិបាលនិងហត្ថលេខីទាំងអស់នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បន្តអនុវត្តឱ្យបានពេញ លេញនិងមានប្រសិទ្ធភាពនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ ។ លើសពីនេះ សូមរដ្ឋាភិបាលកម្ពុជាពិចារណា ដាក់បញ្ចូលទិវា ២៣ តុលា ក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់ជាតិឡើងវិញពីព្រោះវាជាការចាំបាច់ មួយដែរដែលយើងគួរប្រារព្ធទិវានេះជាទិវាជាតិប្រចាំឆ្នាំដើម្បីរំលឹកពីវីរភាព របស់អ្នកដែលបានលះបង់ កម្លាំងកាយ ចិត្ត និងជីវិតដើម្បីបុព្វហេតុសន្តិភាពនៅកម្ពុជា និងដាស់តឿនឱ្យខ្មែរគ្រប់រូបនិងគ្រប់ជំនាន់ចង ចាំទិវាប្រវត្តិសាស្រ្តនេះ ព្រមទាំងបន្តស្មារតីថែរក្សានិងលើកកម្ពស់សន្តិភាព, ក្រោកឈរឡើងចងបាច់គ្នា ប្រកបដោយឆន្ទៈមោះមុត ឯកភាពគ្នា ទទួលខុសត្រូវចំពោះវាសនាអនាគត, កសាងនិងការពារជាតិឱ្យ បានឈានឡើង និងសម្បូររុងរឿងជានិច្ចនិរន្តរ៍៕

សេចក្តីថ្លែងការណ៍នេះគាំទ្រដោយ៖ ក្រុមការងារអង្គការសង្គមស៊ីវិលដើម្បីខួបទី ៣០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

1. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
2. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
3. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
4. អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
5. សម្ព័ន្ធសហជីពប្រជាធិបតេយ្យ កម្មករកាត់ដេរកម្ពុជា (C-CAWDU)
6. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
7. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
8. អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)
9. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (សង់ត្រាល់/ CENTRAL)
10. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
11. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
12. អង្គការវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
13. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
14. បណ្តាញយុវជនកម្ពុជា (CYN)
15. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
16. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
17. អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
18. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
19. អង្គការស្ពានសន្តិភាព (PBO)
20. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)
21. អង្គការសហគមន៍អភិវឌ្ឍន៍មិត្តជនបទ (RCFD)
22. អង្គការស្តារកម្ពុជា (Star Kampuchea)
23. អង្គការសមាគមធាងត្នោត (STT)
24. អង្គការតម្លាភាពកម្ពុជា (TI_Cambodia)
25. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU)
26. អង្គការយុវសន្តិភាព (YFP)
27. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)